ពាក្យថាបុណ្យ **ចិត្តបុថុជ្ជន** ពាក្យថាកុសល

មនុស្សក្នុងលោកនាពេលបច្ចុប្បន្នសុទ្ធសឹងតែជាបុថុជ្ជន គឺជាអ្នកដែលជាប់ជំពាក់ទៅដោយកិលេស តណ្ហា សេចក្តីប្រាថ្នា ការចង់បាន ការឈ្នានីស ភាពក្រអឺតក្រទម មានះរឹងរូស ប្រកាន់អំនួត ប្រកួតអំណាច កោងកាចសព្វអន្លើ ជាខ្ញុំបំរើនៃលោភៈ ទោសៈ និងមោហៈ ។ មិនតែប៉ុណ្ណោះ បុថុជ្ជនតែងតែមានចិត្តទោរទន់ទៅតាមលោកធម៌ដែលជាធម៌នៅជាប់ប្រចាំលើលោកសន្និវាសនេះ *លោកធម៌នោះមាន៨ ប្រការគឺ មានលាភ ឥតលាភ មានយស ឥតយស សរសើរ និន្ទា សុខ និង ទុក្ខ*។ បុគ្គលជាបុថុជ្ជនកាលណាបានទទួលនូវលាភសក្ការៈ មានទ្រព្យសម្បត្តិសម្បូរហូរហៀរ ទទួលនូវសក្តិយសខ្ពង់ខ្ពស់មានអ្នកផងគោរពលើកតំកើង មានអ្នកផងកោតសរសើរលើកបញ្ជោរដោយប្រការផ្សេងៗ រមែងមានចិត្តសប្បាយរីករាយនិងដល់នូវសេចក្តីសុខដែលហៅថាអាមិសសុខ គឺសុខព្រោះតែអាស្រ័យសភាពដូចបានរៀបរាប់មកខាងលើនេះ។ ផ្ទុយទៅវិញ នៅពេលដែលគេ បាត់បង់លាភសក្ការៈ បាត់បង់យសស័ក្តិ ឬជួបនូវការរិះគន់និន្ទាដោយប្រការផ្សេង ក៏រមែងដល់នូវសេចក្តីក្រោធខឹងក្តៅក្រហាយខ្វល់ខ្វាយចិត្តស្ថិតក្នុងសភាពជាទុក្ខឥតស្រាកស្រាន្ត។ ចិត្តរបស់បុថុជ្ជនគឺមានសភាពយ៉ាងនេះ ខុសពីចិត្តរបស់ព្រះអរិយបុគ្គល ព្រោះព្រះអរិយបុគ្គលព្រះអង្គមានព្រះទ័យមិនញាប់ញ័រដោយលោកធម៌ទាំង៨ប្រការនេះ ហើយព្រះអង្គមានមេត្តាករុណាចំពោះសព្វសត្វទាំងអស់ស្មើៗគ្នា ។ មានជាអាទិ៍ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងព្រះអង្គមានព្រះទ័យអាណិតស្រលាញ់សត្វលោកទាំងអស់ស្មើៗគ្នា ដូចជាភិក្ខុទេវទត្តដែលតាមព្យាបាទព្រះអង្គ ព្រះអង្គទ្រង់ស្រលាញ់ស្មើនឹងរាហុលដែលជាបុត្រាបង្កើតរបស់ព្រះអង្គ ។

មានតែយើងជាបុថុជ្ជនប៉ុណ្ណោះ ដែលនៅញាប់ញ័រដោយលោកធម៌និងគ្រឿងសៅហ្មងចងក្រៀក។ គ្រឿងសៅហ្មងទាំងនេះ គឺជាដុំពពកខ្មៅដែលបិទបាំងរារាំងចិត្តមនុស្ស មិនអោយចាក់ធ្លុះនូវសច្ចធម៌ក្នុងលោកបាន និង ជាច្រវាក់ទាក់ក មិនអោយមនុស្សត្រាច់ចរ ទៅកាន់ភាពរុងរឿងថ្កុំថ្កើងបានតាំងពីបុគ្គលម្នាក់រហូតដល់សង្គមទាំងមូល ។ ស្ថិតក្នុងវិស័យរបស់បុថុជ្ជនដែលលិចលង់ក្នុងជំនន់នៃគ្រឿងសៅហ្មងយ៉ាងនេះ បុគ្គលមិនគប្បីផ្តេកផ្តួលទៅតាមលំហូរនៃចិត្តដែលជិតដោយគ្រឿងសៅហ្មងទាំងនេះឡើយ គប្បីធ្វើយ៉ាងណាដើម្បីស្រវាឡើងអោយបានខ្ពស់ រស់ក្នុងនាមជាកល្យាណបុថុជ្ជនដែលជាបុថុជ្ជនដ៏ល្អប្រសើរ ។ ពិតមែនថា បុថុជ្ជនគឺជាជនដែលនៅមានកិលេសតណ្ហា សេចក្តីប្រាថ្នា និង ការចង់បាន

ក៏ដោយ តែមនុស្សជាបុថុជ្ជនគង់មានសភាពប្លែកគ្នាដោយចិត្ត គំនិត និង សតិបញ្ញាស្មារតី ។ បុថុជ្ជនខ្លះមានគំនិតភ្លឺថ្លា បញ្ញាខ្ពង់ខ្ពស់ ស្គាល់បាបស្គាល់បុណ្យ ស្គាល់គុណស្គាល់ទោស ស្គាល់ខុសស្គាល់ត្រូវ ស្គាល់សុខស្គាល់ទុក្ខ ស្គាល់ប្រយោជន៏និងមិនមែនប្រយោជន៏ ចំណែកបុថុជ្ជនខ្លះទៀតមានគំនិតថោកទាបសភាពមិនខ្ពង់ខ្ពស់ មិនស្គាល់ បាប បុណ្យ គុណ ទោស ប្រយោជន៏ និង មិនមែនប្រយោជន៏ជាដើម នេះគឺជាសភាពប្លែកគ្នានៃបុថុជ្ជនទាំងឡាយក្នុងលោកនេះ ។

ហេតុនេះ យើងមិនគួរសំអាងថាខ្លួនជាបុថុជ្ជនហើយចេះតែប្រព្រឹត្តធ្វើនូវ ទង្វើមិនសមហេតុសមផលបានដល់អំពើទុច្ចរិតផ្សេងៗនោះទេ យើងគប្បីប្រឹងរំដោះខ្លួនអោយផុតពីច្រវាក់និងគ្រឿងរាំងស្ទាក់ទាំងឡាយដោយ អាវុធដ៏ប្រសើរគឺ បញ្ញា ។ បើទុកជាយើងមិនអាចរំដោះខ្លួនអោយរួចផុតទាំងស្រុងក្នុងជាតិនេះ ក៏គង់នឹងអាចបណ្តោះបណ្តែសំរាលអោយបានស្រាលស្តើងខ្លះគ្រាន់នឹងបានជាឧបនិស្ស័យបន្តទៅអនាគតនិងជួយពន្លត់នូវភ្លើងអពមង្គលពីមណ្ឌលដួងចិត្តមួយចំនួននាពេលបច្ចុប្បន្ននេះ។ ទឹកដែលស្រក់លេចចេញពីធុងមួយតំណក់ម្តងៗ អាចអស់ពីធុងបានយ៉ាងណា គ្រឿងសៅហ្មងក្នុងចិត្តដែលបុគ្គលព្យាយាមលះបន្តិចម្តងៗម្តងគង់នឹងអស់ទៅនៅពេលណាមួយមិនខាន ។

ចុះបើបុគ្គលគ្មានបញ្ញាដើម្បីធ្វើជាអាវុធប្រយុទ្ធនឹងអវិជ្ជាទេនោះតើត្រូវធ្វើយ៉ាងណា?

ចំណុចនេះហើយដែលព្រះសម្មាសម្ពុទ្ធវិសុទ្ធិវង្សទ្រង់ជាព្រះបរមគ្រូនៃយើង តែងតែខិតខំទេសនាទូន្មានប្រៀនប្រដៅពុទ្ធបរិស័ទទាំងឡាយអោយបានយល់អំពីហេតុដែលនាំអោយកើតបញ្ញានោះ។ ព្រះអង្គទ្រង់សំដែងថា អង្គធម៌ដែលនាំអោយកើតបញ្ញាមានបីយ៉ាងគឺៈ

*ទី-១ បញ្ញាកើតពីការស្តាប់ ឬ ការអាន ( សុត្តមយបញ្ញា) ។*

*ទី-២ បញ្ញាកើតពីការត្រិះរិះពិចារណារកហេតុផល ( ចិន្តមយបញ្ញា) ។*

*ទី-៣ បញ្ញាកើតពីការចំរើនភាវនា គឺអប់រំចិត្តរបស់ខ្លួន អោយស្ថិតនៅក្នុងគុណធម៌ប្រពៃមានរក្សាសីល និង ចំរើនមេត្តាធម៌ជាដើម ( ភាវនាមយបញ្ញា) ។*

ធម៌ទាំងបីប្រការនេះ ជាមូលដ្ឋានគ្រឹះសំរាប់នាំបុគ្គលអ្នកប្រតិបត្តិតាមអោយធ្វើដំណើរទៅរកពន្លឺគឺបញ្ញាកាប់ឆ្ការអវិជ្ជាបើកទ្វារឋានសួគ៌និងព្រះនិព្វាន ឈានទៅរកសេចក្តីសុខនិងសុភមង្គលទាំងលោកនេះ និងបរលោក។ បើបុគ្គលប្រាសចាកធម៌ទាំងបីក្រារនេះហើយមិនអាចនឹងរកឃើញនូវពន្លឺបញ្ញាបានឡើយ ។

ធម្មតាសត្វម្រឹគទាំងឡាយ មិនដែលរត់ចូលទៅក្នុងមាត់សីហៈដែលកំពុងដេកស្រមុកក្នុងគូហារនោះទេ យ៉ាងណាមិញបញ្ញាមិនដែលកើតមានដល់បុគ្គលខ្ជិលច្រអូសទំរន់ទំរេតពេលវេលា វៀវការស្តាប់ការអាន និង ការត្រិះរិះ ពិចារណារិះរកសច្ចធមិនោះដែរ ។

សូមបញ្ជាក់បន្ថែមទៀតថា ពាក្យថាបញ្ញានៅទីនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គទ្រង់សំដៅទៅលើបញ្ញាដែលធ្វើមនុស្សអោយស្គាល់នូវសច្ចធមិ ស្គាល់នូវកងទុក្ខទាំងពួង ហើយនាំខ្លួននិងអ្នកដទៃអោយរួចចាកកងទុក្ខទាំងនោះ បុគ្គលយ៉ាងនេះព្រះអង្គទ្រង់ហៅថាបណ្ឌិត។ ចំណែកបញ្ញាក្នុងការប្រើល្បិចកិច្ចកល ក្រឡិចក្រឡុចក្រឡាប់ផ្កាប់ផ្ងារ ដោយពាក្យមុសា វាចាបំភ្លៃ និងកលមាយាផ្សេង១ប្រជែងយកឈ្នះ ធ្វើទុក្ខបុកម្នេញអោយខូចប្រយោជន៍អ្នកដទៃ ដើម្បីប្រយោជន៍ខ្លួននិងបក្សពួកមួយចំនួននោះ ព្រះសម្មាសម្ពុទ្ធលោកហៅបុគ្គលយ៉ាងនេះ ថាជា បុគ្គលពាល ។

បុថុជ្ជនដែលជាបុគ្គលពាលមានអបាយភូមិ៤ គឺ នរក ប្រេត តិរច្ឆាន និង អសុរកាយជាទីទៅ ចំណែកបុថុជ្ជនដែលជាបណ្ឌិតមានសុគតិគឺឋានមនុស្សនិងឋានសួគ៌ជាដើមជាទីទៅ ។ ដូច្នេះយើងទាំងអស់គ្នាមិនគប្បីប្រមាទចំពោះធមិទាំងឡាយឡើយ គប្បីនាំគ្នាគោរពតាមធមិប្រតិបត្តិតាមធមិអោយបានល្អប្រពៃ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថា បដិបត្តិបូជា ជាការបូជាដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់។

កុំអាងពាក្យថាបុថុជ្ជន បង្កើតទោសទណ្ឌឥតអៀនខ្មាស់
អកុសលកម្មបទបាបក្រៃក្រាស់ គួរគិតអោយច្បាស់កុំវេចស្តាយ ។
កម្មណានាំខ្លួនអោយបានទុក្ខ ដូចឡើងឈើពុកកុំគិតងាយ
កម្មណានាំខ្លួនអោយពណ្ណរាយ ព្រះពុទ្ធទំនាយថាកុសល។
ហេតុនេះគួរខំរៀនធមិអាថ៌ កសាងបញ្ញាទុកតំកល់
ជាផ្លូវសាងល្អរកមគ្គផល នាំកាយឆ្ងាយខ្វល់ដល់សុខា ។
កុំអាងថាខ្ញុំជាប់រវល់ គ្មានពេលស្វែងយល់រឿងធមិអាថ៌
ឯពេលរាំច្រៀងល្បែងសុរា នឿយហត់យ៉ាងណាឆ្លៀតបានខ្លះ ។

# ពាក្យថា "បុណ្យ" ▲

នរជនក្នុងលោកទាំងមូលទោះជាតិណា សាសន៍ណាក៏ដោយតែងតែស្រលាញ់ពេញចិត្តចំពោះពាក្យថាបុណ្យ ចង់បានបុណ្យ ទោះជាប្រើប្រាស់ភាសាខុសគ្នាក្តី ទ្រឹស្តីអប់រំផ្នែកសាសនាខុសគ្នាក្តី តែខ្លឹមសារអត្ថន័យដែលនៅក្នុងចិត្តអ្នកស្តាប់ អ្នកគោរពប្រតិបត្តិតាមនោះៗសុទ្ធតែមានចំណង់ចង់បានរបស់មួយគឺបុណ្យ ។ បើទុកជាមានសាសនាមួយចំនួនមានទ្រឹស្តីអប់រំមិនសមហេតុផលមិនសមស្របទៅតាមសច្ចធម៌ក៏ដោយក៏អ្នកស្តាប់ដែលមិនបានពិចារណារកហេតុផល ហើយបណ្តែតបណ្តោយអោយមនោគមវិជ្ជាសាសនាគ្រប់ដណ្តប់ទាល់តែងប់ងុលជ្រមុលជ្រមុជក្នុងជុចនៃមិច្ឆាទិដ្ឋិទាំងឡាយ ខិតខំគោរពប្រតិបត្តិតាមដោយសារគេជឿថា ការគោរពប្រតិបត្តិរបស់គេនឹងនាំមកនូវបុណ្យ ឯលទ្ធផលជាផ្លែផ្កាទៅជាយ៉ាងណានោះគឺជារឿងសច្ចធម៌ គឺធម៌ដែលមានពិតប្រាកដអោយផលពិតប្រាកដតាមហេតុបច្ច័យដែលបុគ្គលបានតាក់តែងអោយកើតឡើង ។

ពាក្យថាបុណ្យនេះគឺជាពាក្យដែលពេញនិយម ជាពាក្យដែលមនុស្សទូទាំងពិភពលោកស្រលាញ់ចង់បានជាទីបំផុត ខុសគ្នាតែត្រង់ទង្វើដែលគេនាំគ្នាធ្វើអោយកើតបុណ្យប៉ុណ្ណោះ ។ ដោយសារតែមនុស្សទូទៅនាំគ្នាស្រលាញ់បុណ្យ ហើយមានមនុស្សភាគច្រើនមិនបានយល់ច្បាស់ដោយបញ្ញាក្នុងការប្រកបហេតុអោយកើតបុណ្យនេះ ទើបមានជនទុច្ចរិតមួយចំនួនយកពាក្យថាបុណ្យនេះធ្វើជានុយបោកប្រាស់ដោយប្រការផ្សេងៗ ដើម្បីស្វែងរកទ្រព្យសម្បត្តិខ្លះ ស្វែងរកបរិស័ទខ្លះ ស្វែងរកកេរ្តិ៍ឈ្មោះខ្លះ ទៅតាមសេចក្តីត្រូវការនិងគោលនយោបាយរបស់ពួកគេ។ ម៉្យាងទៀត ការមិនស្គាល់ច្បាស់នូវហេតុនៃបុណ្យនេះនាំអោយមនុស្សធ្វើអំពើមិនសមហេតុផលផ្សេងៗដោយស្មានថាជារឿងត្រឹមត្រូវ ដូចជា អ្នកខ្លះចង់បានបុណ្យបែរជាទៅធ្វើបាប អ្នកខ្លះចង់បានបុណ្យក៏ទៅបួងសួងសុំបុណ្យ អ្នកខ្លះចង់បានបុណ្យទៅងូតទឹកលាងបាប អ្នកខ្លះចង់បានបុណ្យបែរជាសំលាប់ខ្លួន ហើយអ្នកខ្លះទៀតចង់បានបុណ្យបែរជាធ្វើទារុណកម្មខ្លួនឯងដោយប្រការផ្សេងៗ ។ល។ ទាំងនេះសុទ្ធតែទង្វើផ្សេងៗគ្នាដែលមនុស្សក្នុងលោកនេះបានប្រតិបត្តិ ហើយអ្នកដែលប្រព្រឹត្តប្រតិបត្តិនោះសុទ្ធតែមានបំណងតែមួយគត់ដូចគ្នាគឺដើម្បីអោយបានបុណ្យ ។

ឥឡូវនេះយើងងាកមកពិនិត្យពិចារណារកន័យខ្លឹមសាររបស់ពាក្យថា បុណ្យ ម្តង តើពាក្យនេះ

មានឫសគល់មកពីណា? មានន័យយ៉ាងណា? ហើយហេតុណាខ្លះដែលអាចអោយកើតបុណ្យបាន?

ក្នុងសេចក្តីជាលំដាប់លំដោយតទៅនេះ សូមអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយប្រិតប្រុងចេតនាពិចារណាអោយបានជិតដល់ចំពោះពាក្យថាបុណ្យនេះ ។

ពាក្យថា "បុណ្យ" គឺជាស័ព្ទដែលមកពីភាសាសំស្ក្រឹត ឯភាសាបាលីហៅថា "បុញ្ញ" ចំណែកភាសាខ្មែរប្រែថា ពេញ អំពើល្អ សេចក្តីសុខ ឬ គុណជាតដែលជំរះសន្តានចិត្តអោយផូរផង់ ។ សមដូចបទវិគ្គហៈថា **សន្តានំ បុណាតិ សោធេតីតិ > បុញ្ញំ** ធម្មជាតឯណាជំរះនូវសន្តានចិត្តអោយផូរផង់ធម្មជាតនោះឈ្មោះថាបុណ្យ ។ ពេលនេះយើងបានស្គាល់ពីខ្លឹមសារនៃពាក្យថាបុណ្យហើយ ប៉ុន្តែយើងត្រូវស្វែងយល់តទៅទៀត ត្រង់វិគ្គហៈដែលថា ធម្មជាតណាជំរះសន្តានចិត្តអោយផូរផង់ធម្មជាតិនោះឈ្មោះថាបុណ្យ ដូច្នេះយើងគប្បីឆ្លល់ថា តើធម្មជាតអ្វីខ្លះ? លួចគេធ្វើអោយចិត្តផូរផង់ទេ? វាយដំច្រំធាក់កាប់សំលាប់គេធ្វើអោយចិត្តផូរផង់ទេ? ផិតក្បត់ភរិយាឬស្វាមីខ្លួនឯងទៅមានសាហាយស្មន់ជាមួយនឹងស្វាមីឬភរិយារបស់អ្នកដទៃធ្វើអោយចិត្តផូរផង់ទេ? និយាយកុហក និយាយចាក់ដោត និយាយព្រុះញង់ និយាយដើមគ្នា ធ្វើអោយចិត្តផូរផង់ទេ? ផឹកនូវសុរាជក់កញ្ឆាអាភៀននាំអោយចិត្តផូរផង់ទេ? គឺសុទ្ធតែមិនអាចធ្វើអោយចិត្តផូរផង់ទាំងអស់ ព្រោះអំពើទាំងនេះមិនមែនជាអំពើនាំមកនូវសេចក្តីចំរើនទាំងខ្លួនអ្នកប្រព្រឹត្តទាំងអ្នកដែលទទួលផលនៃទង្វើ ជាអំពើប្រកបទៅដោយកម្មពៀរ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាជាបញ្ចវេរា គឺពៀរប្រាំប្រការ ។ ចុះការរាំរែកស្រែកច្រៀង ការមើលកុនល្ខោន សុទ្ធតែជាគ្រឿងធ្វើអោយចិត្តអ្នកមើលអ្នកលេងមានចិត្តសប្បាយរីករាយ មានសេចក្តីសុខដែរ ហើយមិនមានបៀតបៀនអោយនរណាកើតទុក្ខទោសផង តើឈ្មោះថាបុណ្យដែរឬទេ? កន្លែងនេះព្រះសម្មាសម្ពុទ្ធព្រះអង្គមិនទ្រង់ចាត់ទុកថាជាបុណ្យទេ ព្រោះថាបើទុកណាជាការនេះមិនប្រព្រឹត្តទៅក្នុងការបៀតបៀនអ្នកដទៃក៏ដោយតែក៏ជាបច្ច័យនៃការបៀតបៀនខ្លួនឯង ដោយអំពើទាំងនេះជាគ្រឿងឧបត្ថម្ភរាគៈទោសៈមោហៈនិងសេចក្តីថ្នាំងថ្នាក់បដិឃៈទាំងឡាយ ។ ការសប្បាយរីករាយទាំងនេះមិនមែនជាឈ្មោះសេចក្តីសុខក្នុងនិយមន័យរបស់បុណ្យនោះទេ បើនិយាយដោយបរមត្ថជាឈ្មោះនៃសេចក្តីត្រេកត្រអាលភ្លើតភ្លើនក្នុងតួលោភៈឯណោះវិញទេ ព្រោះជាធម៌ ដែលបិទបាំងបញ្ញាមិនអោយឃើញនូវអនិច្ចតា ទុក្ខតា និង អនត្តតាធម៌ ។

សភាវៈទាំងនេះហើយដែលអូសទាញសត្វមិនអោយហែលឆ្លងផុតពីសមុទ្រនៃវដ្តសង្សារដ៏សែនធំធេង

វែងឆ្ងាយរកកោះត្រើយគ្មាន ។ បើនិយាយដោយសម្មតិសច្ចៈវិញ បុគ្គលអ្នកញៀនញ៉ាមក្នុងការរាំរែកនិងមើលកុនល្ខោនជាដើមនេះ នាំអោយខូចខាតពេលវេលាក្នុងការបំពេញប្រយោជន៍សំរាប់ជីវភាពប្រចាំថ្ងៃ ខាតបង់ប្រាក់កាសដោយឥតអំពើ ម្យ៉ាងទៀតក្នុងទីប្រជុំជនយ៉ាងនេះសម្បូរទៅដោយពួកពាលដែលបង្កនូវហេតុអកុសលណាមួយ អាចធ្វើអោយរងគ្រោះថ្នាក់ ឬក៏ជាប់ជំពាក់ទាក់ទិនក្នុងការចោទប្រកាន់ណាមួយដែលកើតឡើងជាយថាហេតុ ។ ដូច្នេះទើបព្រះអង្គមិនចាត់ចូលក្នុងនិយមន័យរបស់បុណ្យព្រោះមិនចូលក្នុងមហាកុសលចិត្តទាំងប្រាំបីដូចដែលមានចែងក្នុងបរមត្ថធម៌ ។ ឯធម្មជាតិដែលជំរះចិត្តអោយផូរផង់នោះគឺអំពើដែលបុគ្គលធ្វើទៅហើយ ផ្តល់នូវសេចក្តីសុខសេចក្តីចំរើនត្រជាក់ក្សេមក្សាន្តដល់ខ្លួនអ្នកធ្វើផងដល់អ្នកដទៃផង ដូចជាការលះនូវលោភៈគឺអោយទ្រព្យសម្បត្តិ របស់ខ្លួនធ្វើជាទានដល់អ្នកមានសីលឬជនកំសត់ទុគ៌ត ការលះនូវទោសៈ គឺការរក្សាសីលចំរើនមេត្តាភាវនាមិនគិតប្រទូសដល់សត្វនឹងសង្ខារទាំងឡាយ ការលះនូវមោហៈ គឺបានដល់ចំរើនបញ្ញាអោយបានភ្លឺស្វាងដោយការខំស្តាប់ ខំអាន ខំសាកសួរ ខំត្រិះរិះពិចារណា រកហេតុផលនៃសច្ចធម៌ទាំងឡាយជាដើម ។ ធម្មជាតដូចបានរៀបរាប់មកប៉ុណ្ណេះជាអាទិ៍ឈ្មោះថាជាធម្មជាតជំរះចិត្តអោយផូរផង់ ដុសខាត់នូវកិលេសតណ្ហានានា ធ្វើចិត្តរបស់អ្នកប្រព្រឹត្តអោយស្ថិតក្នុងសេចក្តីជ្រះថ្លាផុតពីសភាពក្តួលក្តៅសៅហ្មង ព្រមទាំងផ្តល់នូវសេចក្តីសុខសន្តិភាពដល់អ្នកភូមិផងរបងជាមួយ បុគ្គលអ្នកប្រព្រឹត្តតែងបានសេចក្តីសុខផ្លូវចិត្តសព្វៗកាល ពេលដេកក៏ជាសុខ ពេលដើរក៏ជាសុខ ពេលចូលជំនុំក៏មានគេគោរពរាប់អានកោតក្រែងដោយគុណធម៌ ឬ សីលគុណរបស់ខ្លួន ។

ពាក្យថាបុណ្យនេះបើពោលជាប្រភេទ អ្នកប្រាជ្ញបណ្ឌិតលោកចែកចេញជា ៣ យ៉ាងគឺ:

**១-ពោលដោយសភាពរបស់ចិត្ត** បានដល់ចិត្តស្អាតផូរផង់ចាកគ្រឿងសៅហ្មងទាំងពួង ជាចិត្តពោរពេញទៅដោយការមិនច្រណែននិន្ទាឈ្នានីសឬស្យា មិនចងអាឃាតព្យាបាទ មិនចងគំនុំគុំគួនបៀតបៀនគ្នានិងគ្នា ទាំងមិនជោរជន់ទៅដោយភាពក្រអឺតក្រទម ប្រកាន់អំនួត ប្រកួតមានះ ជាដើម ។ ជាចិត្តមានមូលដ្ឋានគ្រឹះរឹងមាំក្នុងសភាពជាមេត្តា ករុណាចិត្ត ចេះអាណិត ស្រលាញ់មនុស្សសត្វទូទៅដោយស្មោះស្មើ ប្រាថ្នាអោយមនុស្សសត្វទូទៅរស់នៅដោយសេចក្តីសុខ ត្រជាក់ត្រជំសុខដុមរមនាក្នុងជីវិត ។

**២-ពោលដោយហេតុ** បានដល់ការធ្វើនូវអំពើល្អ អំពើជាកុសលទាំងពួង មានវៀរចាកនូវអកុសលកម្មទាំងបីគឺ កាយទុច្ចរិត ធ្វើអាក្រក់ដោយកាយ វចីទុច្ចរិត ធ្វើអាក្រក់ដោយវាចា មនោទុច្ចរិត ធ្វើអាក្រក់

ដោយចិត្ត ហើយបែរមកប្រកបនូវកុសលសុចរិតទាំងបីគឺ កាយសុចរិត វចីសុចរិត និង មនោសុចរិត វិញ។ ការធ្វើទាន ការរក្សាសីល និង ការចំរើនភាវនា ការជួសង្គ្រោះមនុស្សទូទៅអោយបានសុខសាន្ត ការធ្វើអបចាយនកម្ម គឺគោរពឱនលំទោនចំពោះអ្នកមានគុណធមិ និងសីលគុណ ឬ អ្នកដែលចំរើនដោយវ័យមានចាស់ព្រឹទ្ធាចារ្យជាដើម ដោយហោចទៅសូម្បីតែការចេះដាក់ខ្លួនដាក់កាយ ចំពោះមនុស្សទូទៅ ក៏សុទ្ធសឹងតែជាហេតុដែលនាំអោយកើតបុណ្យទាំងអស់ ។

**៣-ពោលដោយផល** បានដល់សេចក្ដីសុខ កាលណាបុគ្គលមានចិត្តប្រកបដោយសុចរិត គឺចិត្តល្អហើយតែងតែជំរុញអោយមានចេតនាល្អ ចេតនាល្អជាកត្តាជំរុញអោយបុគ្គលនិយាយល្អ និង ធ្វើល្អ ហើយការធ្វើល្អ និយាយល្អនេះឯង ដែលទទួលនូវផលគឺសេចក្ដីសុខ ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ សេចក្ដីសុខផ្លូវកាយកើតឡើងព្រោះបុគ្គលនោះមិនមានពៀរវេរា មិនមានមនុស្សចងគំនុំគុំគួន និង មិនមានសត្រូវប៉ងយាយី។ សេចក្ដីសុខផ្លូវចិត្តកើតឡើងព្រោះបុគ្គលដែលបានប្រព្រឹត្តល្អនោះឯង មិនមានការភិតភ័យ ព្រួយបារម្ភចំពោះភយន្តរាយទាំងឡាយ ព្រោះថា បុគ្គលអ្នកគិតល្អ និយាយល្អ ធ្វើល្អ រមែងមានមិត្តច្រើន មានអ្នកគោរពស្រលាញ់ច្រើន តាមជួយការពារគាំទ្រ មិនអោយមានគ្រោះភ័យនានាចូលមកបៀតបៀន ។ ម្យ៉ាងទៀតផលរបស់បុណ្យតែងបណ្ដាលចិត្តទេវតា អោយតាមជួយថែរក្សាបុគ្គលអ្នកមានបុណ្យធ្វើទុកហើយថែមទាំងជាអំណាចបារមីអាចញ៉ាំងអោយសត្រូវ ឬពួកអមនុស្ស បិសាចនានាដែលប៉ងយាយីមានការខ្លបខ្លាចមិនអាចនឹងចូលមកបៀតបៀនដោយប្រការណាមួយបានឡើយ ។ បុណ្យរមែងអោយផលដល់អ្នកធ្វើដោយមិនរង់ចាំកាលឬចាំជាតិមុខជាតិក្រោយឡើយ ។

ពាក្យ**បុណ្យ**នេះឯងណា ជាភាសាសំស្រ្កឹត
ឯពាក្យបាលីពិត ប្រាជ្ញបណ្ឌិតថា **បុញ្ញៈ** ។
ពាក្យខ្មែរប្រែថា **ពេញ** ផុតទោម្នេញសុខសាន្តជាក់
ធម្មជាតល្អមានល័ក្ខណ៍ ផុតថ្នាំងថ្នាក់ចិត្តផូរផង់ ។
ឈ្មោះបុណ្យឈ្មោះក្ដីសុខ ច្រានក្ដីទុក្ខបន្សាត់បង់
ហេតុនេះគួរផ្ចិតផ្ចង់ សន្សំបុណ្យកុំប្រហែស ។

# ពាក្យថា "កុសល"

នៅទំព័រមុនអាត្មាភាពបានបកស្រាយអធិប្បាយរួចមកហើយអំពាក្យថា បុណ្យ នៅក្នុងទំព័រនេះនឹងសូមវែកញែកបកស្រាយនូវពាក្យថា កុសល បន្តទៀត ។

ពាក្យថា កុសល នេះជាភសាបាលី បើនិយាយដោយន័យអោយស្រួលស្តាប់ស្មើនឹងពាក្យថា បុណ្យ ដែរ ព្រោះជាវេវចនស័ព្ទគឺស័ព្ទដែលប្រើជំនួសគ្នាបាន ។ ខ្មែរយើងនិយមប្រើពាក្យទាំងពីរនេះភ្ជាប់គ្នា ដូចជា ពាក្យថា បុណ្យកុសល ឬ កុសលផលបុណ្យ ជាដើម ។ កុសល បើប្រែដោយសេចក្តីមានពីរយ៉ាងគឺៈ ជានាមស័ព្ទ ប្រែថា *កម្មដែលកំចាត់បង់នូវអំពើអាក្រក់* ឬ ប្រែថា *បុណ្យ* ។ ជាគុណនាមប្រែថា *ដែលល្អប្រពៃ* ឬ *ដែលជាបុណ្យ* ។ម្យ៉ាងវិញទៀត បើយើងប្រែតាមឫសគល់ដែលជាភាសាបាលីនោះមានន័យថា *ឈ្លាស ប៉ិន ប្រសប់ វាងវៃ* ឬ ន័យមួយទៀតថា *គុណជាតគួរក្នុងកិរិយាផ្តាច់បង់នូវបាប* ។ សមដូចបទវិគ្រោះថា កុសេ បាបច្ឆេទនេ អលន្តិ > កុសលំ ប្រែថា (គុណជាត) ផ្តាច់នូវធម៌ដ៏អាក្រក់គឺធម៌ជាអកុសលឈ្មោះថា កុសល ។ យើងគប្បីពិចារណាថាគុណជាតអ្វីដែលផ្តាច់បង់នូវធម៌ដ៏អាក្រក់ ? គុណជាតអ្វីដែលបន្សាត់បង់នូវបាបទាំងពួង? ទង្វើគឺកម្មគ្រប់ប្រភេទដែលជាការកាត់ផ្តាច់ឬបង្រ្កាបបង់នូវធម៌អាក្រក់លាមកថោកទាប ឬហៅថាបាបធម៌ចេញពីក្នុងខន្ធសន្តាន ទង្វើទាំងនោះឈ្មោះថាទង្វើជាកុសលឬកុសលកម្ម យើងហៅបានម្យ៉ាងទៀតថា បុញ្ញកម្ម ។ ដូច្នេះគោលបំណងនៃស័ព្ទទាំងពីរគឺ កុសល និង បុណ្យ ឆ្ពោះទៅកាន់ទិសដៅតែមួយដូចគ្នា គឺកំចាត់បង់នូវកិលេសតណ្ហានិងអាសវធម៌ទាំងឡាយទាញ យកផលតែមួយដូចគ្នាគឺសេចក្តីសុខ ។ ប៉ុន្តែបើយើងពិនិត្យទៅលើអត្ថរបស់ពាក្យនីមួយៗ ពាក្យថា កុសល មានន័យមុតមាំ ក្លៀវក្លានិងមានសន្ទុះខ្លាំងជាងពាក្យថាបុណ្យ ឯតួនាទីនិងកិច្ចប្រតិបត្តិការគឺឆ្ពោះតម្រង់ទៅកាន់ទិសដៅតែមួយដូចបានរៀបរាប់មកហើយ ។

ពាក្យថា កុសលនេះ មានច្រើនថ្នាក់ច្រើនជាន់និងច្រើនប្រភេទទៅតាមឈ្មោះនៃកិច្ចដែលបុគ្គលបានធ្វើ ។ អ្នកដែលធ្វើទានឈ្មោះថាធ្វើកុសលថ្នាក់ទាន អ្នករក្សាសីលឈ្មោះថាធ្វើកុសលថ្នាក់សីល អ្នកចំរើនវិបស្សនាឈ្មោះថាធ្វើកុសលថ្នាក់វិបស្សនា ទៅតាមកាលៈទេសៈ ពេលវេលា និង សមត្ថភាពផ្លូវចិត្តនិងផ្នែកបញ្ញាដែលអាចធ្វើទៅបាន ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងធម៌ប្រោសសត្តនិករអមរឥន្ទព្រហ្មទាំងឡាយដោយមាន

ព្រះពុទ្ធបំណងជួយស្រោយចំណងសព្វសត្វអោយរួចពីអន្ទាក់នៃអវិជ្ជាដែលចងឆ្នាក់សព្វសត្វទាំងឡាយមិនអោយដាច់អាល័យពីលោកិយសុខទាំងឡាយ ។ ព្រះអង្គទ្រង់ចង្អុលបង្ហាញនូវអមតដ្ឋាន ជាឋានដ៏ប្រសើរទ្រង់អោយឈ្មោះថាឯកន្តបរមសុខ គឺសេចក្តីសុខដ៏លើសលប់រកសេចក្តីសុខដទៃអោយស្មើគ្មាន បានដល់ព្រះនិព្វាន ។ សត្វទាំងឡាយណាដែលមានធូលីក្នុងភ្នែកតិច គឺមានរាគៈ ទោសៈ មោហៈ ស្តើងក៏អាចសម្លឹងឃើញនូវព្រះនិព្វានថាជាស្ថានសុខដ៏ក្រៃលែង ហើយខិតខំប្រតិបត្តិទៅតាមគន្លងអរិយមគ្គមានអង្គ ៨ សន្សំបុណ្យកុសលដើម្បីកាត់ផ្តាច់នូវអាសវក្កិលេសទាំងឡាយ ធ្វើដំណើរទៅកាន់ព្រះនិព្វានតាមការចង្អុលបង្ហាញរបស់ព្រះអង្គ ។ សត្វណាដែលមានធូលីក្នុងភ្នែកក្រាស់ គឺមាន លោភៈ ទោសៈ មោហៈ ច្រើន មិនអាចមានបញ្ញាពិចារណានូវទោសនៃវដ្តសង្សារបាន ក៏តែងតែចង់វិលវល់អន្ទោលក្នុងវដ្តសង្សារ ប្រាថ្នាសេចក្តីសុខសេចក្តីសប្បាយក្នុងកាមគុណទាំង៥ គឺ រូប សំលេង ក្លិន រស និង ផោដ្ឋព្វៈ គឺការពាល់ត្រូវ មិនដាច់ចិត្តគិតនឹងលះបង់នូវវត្ថុកាមទាំងឡាយព្រោះស្ថាយស្រណោះ ទៅតាមអំណាចនៃការបង្គាប់បញ្ជារបស់ព្រះនាងអវិជ្ជាទេវី ។

ហេតុដូច្នេះហើយបានជាព្រះបរមលោកនាថសព្វញ្ញុពុទ្ធវិសុទ្ធលើសលោក ទ្រង់សំដែងបែងចែកនូវកុសលថាមានពីរប្រការគឺៈ

**១-វដ្តគាមិនីកុសល** កុសលដែលបុគ្គលធ្វើដោយសេចក្តីប្រាថ្នានូវជាតិភព ។ ជាកុសលដែលបុគ្គលធ្វើដើម្បីចង់បានសេចក្តីសុខក្នុងលោកជាផល មានប្រាថ្នាយកឋានមនុស្ស ឋានសួគ៌ និងជាន់ព្រហ្មលោក ជាដើម ។ ក្នុងនាមជាបុថុជ្ជនដែលធ្ងន់ទៅដោយអវិជ្ជា រមែងមានលោភៈ ទោសៈ និង មោហៈ ជាធម្មតា ដែលហៅថាឫសគល់នៃអកុសល ឬហៅថា អកុសលមូល ។ អកុសលមូលនេះរមែងបិទបាំងសត្វមិនអោយយល់ឃើញនូវធម៌ពិត តែងតែធ្វើអោយមានការភាន់ច្រឡំសំគាល់ខុសទៅក្នុងរឿងផ្សេងៗ ។ សត្វលោកមួយចំនួនធំតែងតែមានចិត្តជាប់ជំពាក់ទៅលើសេចក្តីសុខក្នុងលោកិយថាជាសុខដ៏ប្រសើរ ហេតុដូច្នេះហើយទើបធ្វើអោយសត្វមិនអាចមើលឃើញនូវព្រះនិព្វានថាជាឯកន្តបរមសុខ ។ គេមើលឃើញត្រឹមតែសេចក្តីសុខក្នុងភព ក្នុងជាតិកំណើត ជាប់ចិត្តញៀនញ៉ាមនឹងបញ្ចកាមគុណ ហើយក៏ខិតខំធ្វើបុណ្យកុសលតាំងសេចក្តីប្រាថ្នាដើម្បីអោយបាននូវសម្បត្តិនោះៗ។ ដូចដែលលោកអ្នកសប្បុរសធ្លាប់បានដឹងបានឮស្រាប់ហើយ ហើយជួនកាលលោកអ្នកផ្ទាល់ក៏ធ្លាប់បានគិតក្នុងចិត្តខ្លួនឯងហើយដែរថា មិនចង់ទៅ

*ទេនិព្វានព្រោះនិព្វានគ្មានអ្វីគួរសប្បាយសោះ បើទៅហើយសូន្យឈឹងមិនមានការកើតទៀតអញ្ចឹង ទៅធ្វើអ្វី សុំទៅត្រឹមតែឋានសួគ៌ ប៉ុណ្ណឹងអស់ចិត្តហើយ។ មានអ្នកខ្លះទៀតនៅជាប់ចិត្តក្នុងភពកំណើតជាមនុស្សមិនចង់ទៅកើតឋានសួគ៌ ព្រោះគិតថា ឋានសួគ៌មិនមានម៉ូតូឡានយន្តហោះដើម្បីជិះ មិនមានបនល្បែងហាងសុរា ខារ៉ាអូខេ និងកាស៊ីណូជាដើម ម្ល៉ោះហើយនឹងគ្មានអ្វីគួរជាទីសប្បាយជាទីរីករាយឡើយ ។*

កាលបើមានចិត្តគិតស្ដាយបញ្ចកាមគុណដូច្នេះហើយ គ្រប់ពេលធ្វើបុណ្យកុសលផ្សេងៗក៏តាំងសេចក្ដីប្រាថ្នាដើម្បីបាននូវជាតិភពដែលខ្លួនចង់បាន ដូចជា បើកើតជាមនុស្សក៏សូមអោយមានរូបកាយស្រស់ស្អាត ទ្រព្យសម្បត្តិហូរហៀរ មានបរិវារច្រើន មានអាយុវែង មានសេចក្ដីសុខគ្រប់យ៉ាង បើកើតក្នុងឋានសួគ៌ក៏សូមអោយមានទិព្វសម្បត្តិ មានបុណ្យបារមីខ្លាំងក្លានិងទេពធីតាជាបរិវារតាមហែរហមអមដំណើរ សោយសុខក្នុងទិព្វវិមាន ដូច្នេះជាដើម ។

សេចក្ដីប្រាថ្នាក្នុងភពជាតិដូចបានរៀបរាប់មកនេះឈ្មោះថា វដ្ដគាមិនីកុសល គឺកុសលដែលជាបច្ច័យអោយសត្វវិលវល់អន្ទោលទៅក្នុងវដ្ដសង្សារវែងឆ្ងាយតទៅទៀត ព្រោះកុសលបែបនេះមិនអាចនាំសត្វអោយផុតទុក្ខបានឡើយ ដោយហេតុថា សេចក្ដីសុខក្នុងសម្បត្តិមនុស្សនិងសម្បត្តិទេវតាឥន្ទព្រហ្មទាំងឡាយ សុទ្ធតែស្ថិតនៅក្នុងសាមញ្ញលក្ខណធមិបីយ៉ាង គឺ អនិច្ចំ ទុក្ខំ និង អនត្តាតែងមានមានការប្រែប្រួលសោះសូន្យទៅជាធម្មតា ហើយពេលណាមួយនឹងអាចធ្លាក់ចូលទៅក្នុងអបាយភូមិ មាននរក ប្រេត តិរច្ឆាន និង អសុរកាយ វិលវល់ឡើងចុះៗ ទៅតាមកំលាំងនៃកុសលនិងអកុសលដែលខ្លួនបានកសាង ។

**២-វិវដ្ដគាមិនីកុសល** កុសលដែលបុគ្គលធ្វើដោយមិនមានសេចក្ដីប្រាថ្នានូវជាតិភព ។ កុសលទីពីរនេះជាកុសលថ្នាក់លោកុត្តរៈ គឺជាបច្ច័យនាំសត្វអោយឆ្លងផុតពីសង្សារវដ្ដមិនមានការបង្កើតកំណើតជាតិភពតទៅទៀតឡើយ ។ បុគ្គលអ្នកធុញទ្រាន់ក្នុងសភាពដដែលៗ កើតស្លាប់ៗ កើតក្នុងកំណើតជាអនេកជាតិ មានជាតិ ជរា ព្យាធិ និង មរណៈ តាមយាយីគ្រប់ភពគ្រប់ជាតិ មានចិត្តនឿយណាយនឹងបញ្ចក្ខន្ធ័ ដែលប្រកាន់ខ្ជាប់ដោយឧបាទាន ពិចារណាឃើញកងសង្ខារថាជាទុក្ខ មិនស្ថិតស្ថេរចិរកាល កើតឡើងហើយតែងបែកធ្លាយទៅវិញជាធម្មតា រមែងមានចិត្តចង់ចាកចេញអោយផុតពីសភាវធម៌ទាំងឡាយ

នេះ ។ កាលណាមានចិត្តនឿយណាយចំពោះកាយនិងសង្ខារហើយរមែងសម្លឹងឃើញនូវព្រះនិព្វានថា ជាឋានដ៏បរមសុខ ជាឋានគ្មានការប្រែប្រួល ផុតពីសភាពអនិច្ចំនិងទុក្ខំ ព្រោះសេចក្តីសុខក្នុងព្រះនិព្វាន ជាសេចក្តីសុខដ៏ពិតប្រាកដ ជានិរាមិសសុខ គឺសេចក្តីសុខដែលគ្មានលោកិយសុខមកចូលលាយឡំ។ សេចក្តីសុខក្នុងព្រះនិព្វាននេះ ព្រះអរិយបុគ្គលអង្គខ្លះពេលដែលបានសំរេចអរហត្តផលភ្លាមព្រះអង្គឧទានវាចាសរសើរថា សុខណាស់ ហ្ន៎ៗ ដូច្នេះជាដើម ព្រោះជាសេចក្តីសុខប្លែកខុសពីលោកិយសុខដែលសត្តនិករជាបុថុជ្ជនកំពុងតែរក់រង្វេងប្រជែងដណ្តើមគ្នា។

ដោយការពិចារណាឃើញនូវតម្លៃដ៏លើសលប់នៃព្រះនិព្វាន ដូច្នេះហើយ បុគ្គលអ្នកនឿយណាយក្នុងកាមគុណនិងពញ្ចក្ខ័ន្ធដ៏ជាទុក្ខ រមែងធ្វើបុណ្យកុសលតាំងសច្ចា ប្រាថ្នាយកព្រះនិព្វាន ស្វះស្វែងសិក្សាធម៌អាចិបដិបត្តិតាមអង្គនៃអរិយមគ្គទាំង៨ ដើម្បីរលាស់ចោលនូវបញ្ចក្ខន្ធ័ តាំងចិត្តឆ្ពោះតម្រង់ទៅកាន់ព្រះនិព្វានដែលជានិរោធសច្ចៈ ។ កាលដែលបុគ្គលមានចិត្តជាកុសលតំកល់ស៊ប់ឆ្ពោះទៅរកព្រះនិព្វានហើយ រមែងបានដល់ព្រះនិព្វានក្នុងជាតិណាមួយយ៉ាងឆាប់រហ័ស ។ វិវដ្តគាមិនីកុសលនេះ គឺជាកុសលដ៏ខ្ពង់ខ្ពស់ដែលព្រះអរិយបុគ្គលទាំងឡាយបានបំពេញដើម្បីកំចាត់បង់នូវកងទុក្ខទាំងពួង រលាស់ចោលនូវបញ្ចក្ខ័ន្ធឆ្ពោះទៅកាន់ព្រះនិព្វានកាត់ផ្តាច់នូវសង្សារវដ្តជាសមុច្ឆេទ ។

ហេតុនេះ កុសលគឺជាឈ្មោះនៃសភាវធម៌ដែលកាត់ផ្តាច់នូវធម៌អាក្រក់គឺអកុសលឬបាបនោះឯង។

ពាក្យកុសល ផ្តល់អត្ថន័យ លៃសំរេច
ការកាត់ផ្តាច់ កាច់បាបធម៌ ដ៏លាមក
ផ្ចាញ់អកុសល ផលសាំញ៉ាំ កម្មគំរក់
មិនលង់លក់ វក់ប្រាថ្នា ការអប្រិយ ។
កម្មកុសល ផ្តល់ឋានសួគ៌ គួរខំសាង
កុំអួតអាង កាងអុងអាត់ ថាមិនអី
កម្មកុសល ផ្តល់និព្វាន ឋានសុខី
កុំធ្វើហី លៃអោយទាន់ គ្រាន់រួចទុក្ខ ។